ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

ក្រុមប្រឹក្សាបច្ចេកទេសលើកទី០២របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី០២ សម្រាប់ឆ្នាំ២០១៩ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍និងជំងឺអេដស៍។កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-បទបង្ហាញពីរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីគោលការណ៍ណែនាំជាតិ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកលសម្រាប់វិស័យមិនមែនសុខាភិបាល។

-បទបង្ហាញពីសេចក្តីព្រាងគោលការណ៍ណែនាំជាតិ ស្តីពីការគ្រប់គ្រងទិន្នន័យឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

-និងបញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**ប្រធានបទទី១**: បទបង្ហាញពីរបាយការណ៍សកម្មភាព និងលទ្ធផលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំខែមីនា ឆ្នាំ២០១៩ ដោយ**លោកវេជ្ជបណ្ឌិត ទេព ណារិទ្ធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៖

**ក- សកម្មភាព និងលទ្ធផលសម្រេចបាន៖**

- ✓ បានបញ្ចប់ការចងក្រងរបាយការណ៍វឌ្ឍនភាពទូលំទូលាយ និងពហុវិស័យ ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨ និងបញ្ចូលក្នុងគេហទំព័ររបស់ អ.ជ.ប.ជ.អ។

- ✓ ថ្ងៃទី៥ និងទី៦ ខែមីនា ឆ្នាំ២០១៩ នៅខេត្តប៉ៃលិន បានរៀបចំសិក្ខាសាលាស្តីពីវឌ្ឍភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨ និងធ្វើផែនការសកម្មភាពរបស់អ.ជ.ប.ជ.អ ឆ្នាំ២០១៩។
- ✓ ការសិក្សាស្តីពីសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ឆ្នាំ២០១៩ (Stigma Index 2:0, 2019) ដោយបានបញ្ចប់ការប្រមូលទិន្នន័យពីគ្រប់ខេត្ត ក្រុមគោលដៅ និងកំពុងសម្អាតទិន្នន័យ។
- ✓ សម្របសម្រួលចងក្រងរបាយការណ៍វឌ្ឍនភាពក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ផ្ញើទៅអង្គការសហប្រជាជាតិឆ្នាំ២០១៩ (GARPR 2019)។
- ✓ បានរៀបចំផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ ដើម្បីដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ លើកទី៥។
- ✓ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការរៀបចំផែនការយុទ្ធសាស្ត្រជាតិលើកទី៥ ដោយបានបញ្ចប់សេចក្តីព្រាងឯកសារការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍លើកទី៤។
- ✓ ថ្ងៃទី២៥ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ ចូលរួមសិក្ខាសាលាថ្នាក់តំបន់នៅទីក្រុងបាងកក ស្តីពីការប៉ាន់ប្រមាណអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដោយប្រើប្រាស់កម្មវិធី *Spectrum* និង *AIDS Epidemic Model* ដោយបានបញ្ចប់សេចក្តីព្រាងទិន្នន័យនៅថ្នាក់ជាតិ និងបានធ្វើការប៉ាន់ប្រមាណនៅថ្នាក់ក្រោមជាតិនៅថ្ងៃទី១៤ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។
- ✓ ថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្កើរបរិយាកាសគាំទ្រ ច្បាប់ និងគោលនយោបាយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់មន្ត្រី អ.ជ.ប.ជ.អ ថ្នាក់រាជធានី និងខេត្តគោលដៅ មានអ្នកចូលរួមចំនួន៥៥នាក់ និងរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការងារនេះប្រចាំត្រីមាស ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ដោយមានអ្នកចូលរួម៣០នាក់ ។
- ✓ ថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ បានផ្សព្វផ្សាយពីបច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ការប្រឈម និងវិធីបង្ការនៅអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទភូមិភាគ២ និងនៅសាលាហ្វឹកហ្វឺនពលទាហានទី២ នៅស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ។
- ✓ បានសហការជាមួយសហព័ន្ធបាល់ទាត់កម្ពុជា ក្នុងការផ្សព្វផ្សាយសារអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងព្រឹត្តិការណ៍ប្រកួតបាល់ទាត់ជាតិ និងអន្តរជាតិ។

- ✓ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ អ.ជ.ប.ជ.អ បានរៀបចំសិក្ខាសាលាស្តីពីការកំណត់ទស្សនវិស័យសម្រាប់ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ដែលមានគោលបំណងសំខាន់ៗ ត្រូវតែសម្រេចឱ្យបានក្នុងឆ្នាំ២០២៣។ ការងារបន្តគឺរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥។
- ✓ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាស្វែងរកចំណុចរួមក្នុងការដាក់ចេញវិធានការទាក់ទងនឹងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (ការអនុវត្ត ស.ជ.ណ លេខ២១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី)។
- ✓ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំក្រុមការងារដឹកនាំរួមស្តីពីការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការរៀបចំផែនការយុទ្ធសាស្ត្រជាតិលើកទី៥ ដោយផ្តោតលើមាតិកា និងគោលគំនិតសំខាន់ៗ សម្រាប់រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥។
- ✓ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ រៀបចំកិច្ចប្រជុំក្រុមការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងប្រទេសកម្ពុជាដើម្បីពិនិត្យមើលវឌ្ឍនភាពនៃចីរភាពក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ រួមមាន ស.ជ.ណ ២១៣ និងបញ្ហាថវិកាគាំទ្រគ្លីនិកឈូកស និងមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម។
- ✓ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងពិភាក្សាជាមួយដៃគូពាក់ព័ន្ធ ដើម្បីពិភាក្សាបញ្ចប់គោលការណ៍ណែនាំស្តីពីការការពារការឆ្លងមេរោគអេដស៍ជាសកល ក្នុងវិស័យមិនមែនសុខាភិបាល។
- ✓ ក្រសួងកិច្ចការនារីបានបញ្ជ្រាបការអប់រំផ្សព្វផ្សាយការបង្ការ និងទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការកសាងទំនាក់ទំនងរវាងមាតា និងយុវតីទាក់ទងនឹងសុខភាពបន្តពូជ សុខភាពផ្លូវភេទ នៅខេត្តព្រះវិហារ ដោយមានការចូលរួមពីមន្ត្រីកិច្ចការនារីខេត្ត ស្រុក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សរុបចំនួន៥០នាក់ (ស្ត្រី ៤៨នាក់) និងវេទិកាអប់រំសហគមន៍ស្តីពីយេនឌ័រ សុខភាពបន្តពូជ និងអាហារូបត្ថម្ភ ដើម្បីបង្កើនការយល់ដឹងជូនប្រជាជនពលរដ្ឋស្តីពីយេនឌ័រ និងអាហារូបត្ថម្ភ សុខភាពបន្តពូជ និងសិទ្ធិការថែទាំសុខភាពក្នុងកំឡុងពេលមានផ្ទៃពោះ មុននិងក្រោយសម្រាល ការបង្ការ និងការទប់ស្កាត់ការឆ្លងមេរោគអេដស៍និងជំងឺអេដស៍ សរុបចំនួន៣៨៦នាក់ ស្ត្រី២២៦នាក់ នៅខេត្តត្បូងឃ្មុំ ។

**ខ- សកម្មភាពបន្ត៖**

- ✓ បន្តការងាររៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៩ ដល់២០២៣។
- ✓ បន្តការងារការសិក្សាស្តីពីសន្ទស្ស នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ឆ្នាំ២០១៩ (Stigma Index 2:0, 2019) ដោយវិភាគទិន្នន័យ និងសរសេររបាយការណ៍។
- ✓ បន្តការងារអនុវត្ត ស.ជ.ណ ២១៣ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធស្របតាមលទ្ធផលកិច្ចប្រជុំអន្តរក្រសួងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។
- ✓ បន្តការងារការបង្កបរិយាកាសគាំទ្រផ្លូវច្បាប់ គោលនយោបាយ កម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- ✓ ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី១ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ នៅខេត្តកែប។
- ✓ ក្រសួង ស្ថាប័ន អង្គការដៃគូត្រូវផ្ញើរបាយការណ៍មកអ.ជ.ប.ជ.អ ឱ្យបានមុនថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ (លោក សាយ ប៊ុណ្ណា say.bunna168@gmail.com, លោកស្រី ឈឹម ម៉ូនីន moninchhoem@gmail.com)។

**គ- តារាងពេលវេលាសម្រាប់ការរៀបចំ NSP V៖**

- ✓ រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣(ខែមីនា ខែមេសា ឆ្នាំ២០១៩)។
- ✓ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមការងារ NSP IV Review & NSP V Development (ខែមីនា ខែមេសា ឆ្នាំ២០១៩)។
- ✓ សិក្ខាសាលាពិគ្រោះយោបល់ និងអនុម័តសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ខែឧសភា ឆ្នាំ២០១៩)។
- ✓ បញ្ចប់សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ខែឧសភា ឆ្នាំ២០១៩)។
- ✓ សិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ខែមិថុនា ឆ្នាំ២០១៩)។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានអនុវត្តកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

➢ តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចៈ សម្រាប់ខែមីនា ឆ្នាំ២០១៩នេះពុំទាន់បានចុះផ្សព្វផ្សាយពីច្បាប់អេដស៍នៅឡើយទេតែបានបញ្ជ្រាបពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់ប្រជាពលរដ្ឋទូទៅគ្រប់វេទិការផ្សព្វផ្សាយច្បាប់ នៅ៨ក្រុង ស្រុក នៅលើ៤ខេត្ត ដោយមានអ្នកចូលរួម៣១២៧នាក់ ស្រីចំនួន១២៧១នាក់។

➢ តំណាងក្រសួងព័ត៌មានៈ បានរៀបចំសិក្ខាសាលាគណៈកម្មាការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងព័ត៌មាន ដោយមានការចូលរួមពីអគ្គនាយកដ្ឋានទាំង៥ អ្នកយកព័ត៌មានរដ្ឋ និងឯកជន ចំនួន៤០រូប តាមរបៀបវារៈ ១-បន្តផ្សព្វផ្សាយលិខិត១៥២៣៣ពម ស្តីពីការផ្សព្វផ្សាយអប់រំពីមេរោគអេដស៍ នៅតាមប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជន។ ២-បន្តផ្សព្វផ្សាយសារអប់រំបង្ការមេរោគអេដស៍ និងច្បាប់អេដស៍។ ៣-ផ្សព្វផ្សាយសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៨ និងលិខិតលេខ២១៣ សជណ.សស របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

➢ តំណាងកាកបាទក្រហមកម្ពុជាៈ គម្រោងបង្ការជំងឺអេដស៍លើជនចំណាកស្រុក ដែលធ្វើនៅលើ៣ប្រទេស(កម្ពុជា ឡាវ និងថៃ) ដោយផ្តោតសំខាន់ទៅលើជនចំណាកស្រុកពីប្រទេសកម្ពុជា ឡាវ ទៅក្នុងប្រទេសថៃ ដោយផ្តល់ការអប់រំ និងធ្វើយ៉ាងណាសម្រួលឱ្យគាត់បានទទួលឱសថប្រឆាំងមេរោគអេដស៍ឱ្យបានទៀងទាត់។ ដោយគម្រោងនេះមានទំហំទឹកប្រាក់រហូតដល់៦០ម៉ឺនដុល្លាអាមេរិក ពីខាងប្រទេសអ៊ីតាលី ប៉ុន្តែខាងប្រទេសអ៊ីតាលី ដែលជាម្ចាស់ជំនួយស្នើឱ្យធ្វើការសាកល្បងសិន។ ពេលនេះបានធ្វើសំណើសម្រាប់សាកល្បងមានទឹកប្រាក់ប្រហែល១០ម៉ឺនដុល្លាអាមេរិកសម្រាប់ប្រទេសទាំង៣។ សម្រាប់ប្រទេសកម្ពុជា បានជ្រើសយកតំបន់ប៉ោយប៉ែត ព្រោះមានប្រជាជនចំណាកស្រុកច្រើន។

**<u>ប្រធានបទទី២</u>**ៈ បទបង្ហាញពីគោលការណ៍ណែនាំជាតិ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ ជាសកលសម្រាប់វិស័យមិនមែនសុខាភិបាល បង្ហាញជូនដោយ **លោកវេជ្ជ. ឪុខ យ៉ាណារាត** ប្រធាននាយកដ្ឋានបង្ការ ថៃទាំ និងគាំទ្រៈ

**គោលបំណងៈ**

✓ គោលការណ៍ណែនាំនេះបានរៀបចំឡើង ក្នុងគោលបំណងចូលរួមបង្ការការចម្លងមេរោគអេដស៍ជាសកល *(ទូទៅ)* គឺការបង្ការការចម្លងមេរោគពីអ្នកទទួលសេវាម្នាក់ទៅម្នាក់ទៀតដោយសារឧបករណ៍មិនស្អាត និងការធ្វេសប្រហែសរបស់អ្នកផ្តល់សេវា។

✓ ដូចនេះអ្នកផ្តល់សេវាដែលពាក់ពន្ធ័គ្រប់រូប ត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍បង្ការជាសកល ចំពោះឈាម ឬវត្ថុរាវសរីរៈរបស់អ្នកទទួលសេវាទាំងអស់ នៅពេលដែលមានការប្រឈមទៅនឹងការប៉ះពាល់ផ្ទាល់ជាមួយអ្នកទទួលសេវាដូចជាៈ អ្នកជំងឺ អ្នករងគ្រោះ ឬ

អតិថិជន ឬក្នុងករណីជួយពិនិត្យ ថែទាំ និងជួយសង្គ្រោះ។ម្យ៉ាងទៀតដើម្បីចូលរួមអនុវត្តនូវមាត្រា១៧នៃច្បាប់អេដស៍ ដែលបានចែងថា " ឈាម ជាលិកា និងសរីរាង្គដែលមានមេរោគអេដស៍ត្រូវតែកំទេចចោលស្របតាមគោលការណ៍អនាម័យឱ្យបានត្រឹមត្រូវបំផុត"។ ក្នុងករណីចាំបាច់ ឈាម ជាលិកា ឬសរីរាង្គដែលមានមេរោគអេដស៍ អាចទទួលយកបានសម្រាប់តែការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រប៉ុណ្ណោះ។

**វិធីសាស្ត្រនៃការបង្ការការចម្លងមេរោគអេដស៍ជាសកលៈ**

- ដើម្បីធានាដល់ការបង្ការការចម្លងមេរោគអេដស៍ជាសាកលឱ្យមានប្រសិទ្ធភាពខ្ពស់ អ្នកផ្តល់សេវាត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវវិធីសាស្ត្រមួយចំនួនដូចខាងក្រោម៖

✓ ត្រូវលាងសម្អាតដៃ *(ជាមួយសាប៊ូ ឬ អាល់កុល)* បន្ទាប់ពីប៉ះពាល់ជាមួយអ្នកជំងឺ ឬអ្នកមកទទួលសេវា និងបន្ទាប់ពីដោះស្រោមដៃចេញ។

✓ ត្រូវលាងសម្អាតភ្លាមៗ *(ជាមួយសាប៊ូ ឬ អាល់កុល)* បន្ទាប់ពីប៉ះពាល់ផ្ទាល់ជាមួយវត្ថុរាវសរីរៈ ឬឈាមរបស់អ្នកជំងឺ ឬអ្នកមកទទួលសេវា។

✓ ត្រូវពាក់ស្រោមដៃប្រសិនបើដឹងថានឹងមានការប៉ះពាល់ជាមួយឈាម ឬវត្ថុរាវសរីរៈ។

✓ ត្រូវពាក់វ៉ែនតា របាំងមុខ និងអៀម បើដឹងថានឹងអាចមានការសាចឈាម ឬវត្ថុរាវសរីរៈ។

✓ កាន់ និងចោលវត្ថុមុតស្រួចឱ្យមានសុវត្ថិភាព ដូចជាម្ជុល កាំបិតកោរ កាំបិតវះកាត់ ឡាម...

✓ សម្អាត និងរំងាប់មេរោគដោយប្រើសារធាតុកំចាត់មេរោគលើឈាម ឬវត្ថុរាវសរីរៈដែលកំពប់ ឱ្យបានត្រឹមត្រូវ។

✓ ត្រូវចាត់ទុកថារាល់កាកសំណល់ ដែលប្រលាក់ឈាម ឬវត្ថុរាវសរីរៈ អាចឆ្លងមេរោគបាន និងត្រូវបោះវាចោលដោយដាក់ទៅក្នុងធុងសំរាមដែលមានសុវត្ថិភាព។

**យន្តការនៃការអនុវត្ត វិធានការបង្ការមេរោគអេដស៍ជាសកលៈ**

- ដើម្បីអនុវត្ត និងគាំទ្រវិធានការបង្ការជាសកល និងដើម្បីពិនិត្យរាល់បញ្ហាឡើងវិញ ក្នុងការដោះស្រាយចាំបាច់ ត្រូវកំណត់ និងជ្រើសរើសជនបង្គោលនៅក្នុងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីបង្កើតឱ្យមានជាគណៈកម្មាធិការ ឬក្រុមការងារអនុវត្តគោលការណ៍ណែនាំ អនុវត្តវិធានការបង្ការជាសកល ដែលត្រូវមានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖
    - សម្រេចយកវិធានការបង្ការណាដែលអាចអនុវត្តទៅបាន (ការសម្រេចចិត្តនេះដោយពឹងផ្អែកទៅលើលទ្ធភាពធនធានដូចជាៈ សម្ភារ ថវិកា មនុស្ស។ល។ និងការវាយតម្លៃពីទំហំគ្រោះថ្នាក់នៃការប្រឈមនឹងការចម្លងមេរោគអេដស៍)។

- ជានាឱ្យមានគោលការណ៍ណែនាំ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល ធ្វើការបែងចែក និងផ្សព្វផ្សាយឱ្យបានដល់គ្រប់ស្ថាប័នដែលពាក់ពន្ធ័ទាំងអស់។
- ផ្តត់ផ្គង់សម្ភារ និងបរិក្ខារសម្រាប់អនុវត្តគោលការណ៍ណែនាំនេះឱ្យបានគ្រប់គ្រាន់
- ធ្វើការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ជនបង្គោលស្តីពីការបង្ការជាសកល
- តាមដាន និងវាយតម្លៃនូវប្រសិទ្ធិភាពនៃការអនុវត្តគោលការណ៍ណែនាំស្តីពីការបង្ការជាសកលនៅក្នុងស្ថាប័ននីមួយៗ។
- ស្រាវជ្រាវរកករណីស្គាល់ ឬករណីសង្ស័យនៃការប្រឈមនឹងគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍ និងផ្តល់អនុសាសន៍ ដើម្បីជៀសវាងគ្រោះថ្នាក់នៅពេលអនាគត។

**ការផ្តល់ព័ត៌មាននៅពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍៖**

ប្រសិនបើមានការសង្ស័យថា មានការប្រឈមទៅនឹងការឆ្លងមេរោគអេដស៍ ត្រូវអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម៖

- រាយការណ៍ដល់គ្រូពេទ្យជំនាញដែលនៅជិតកន្លែងស្នាក់នៅ ឬក្នុងស្ថាប័នរបស់ពួកគេ
- លាងសម្អាតឈាម ឬសារធាតុរាវសរីរៈដែលប្រលាក់ជាបន្ទាន់
- ច្របាច់ឈាមចេញ បន្ទាប់មកលាងនឹងសាប៊ូ ឬប្រើទឹកលាងដែលមានចំនួនច្រើន
- ប្រសិនបើមានឈាមមកប៉ះភ្នែក ត្រូវលាងសម្អាតភ្នែកដោយថ្នមៗជាមួយទឹកធម្មតា ឬទឹកអំបិល ត្រូវបើកភ្នែកពេលលាងម្តងៗ។
- ប្រសិនបើមានឈាមចូលមាត់ ត្រូវស្តោះវាចេញ រួចខ្ពុរមាត់ដោយទឹកធម្មតា
- ផ្តល់ព័ត៌មានពីគ្រោះថ្នាក់នេះដើម្បីងាយស្រួលក្នុងការតាមដាន
- បញ្ជូនអ្នកប្រឈមទៅកន្លែងផ្តល់សេវាព្យាបាលបង្ការការចម្លងមេរោគអេដស៍
- ផ្តល់វិធានការបង្ការការចម្លងមេរោគអេដស៍ក្រោយការប្រឈមនឹងការឆ្លងមេរោគអេដស៍

លោកស្រី **និត សុផា** តំណាងអង្គការ FHI 360 បានសំណូមពរដល់ក្រសួងសុខាភិបាលចេញនូវគោលការណ៍ណែនាំពីការបង្ការការចម្លងមេរោគអេដស៍ជាសកលឱ្យបានឆាប់ ដើម្បីមណ្ឌលសុខភាពអាចផ្តល់សេវាបានជូនដល់អតិថិជនទូទៅ។

បន្ទាប់មកឯកឧត្តមប្រធានអង្គប្រជុំ បានមានប្រសាសន៍ថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងស្នើទៅក្រសួងសុខាភិបាលឱ្យពន្លឿននូវការងារនេះព្រោះវាជាការចាំបាច់ និងស្នើទៅក្រសួងសុខាភិបាលឱ្យមកបង្ហាញពីបញ្ហានេះនៅកិច្ចប្រជុំលើកក្រោយ។

**ប្រធានបទទី៣**: **ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ២១៣ សជណ.សសចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៦ចំណុច ដើម្បីដាក់ចេញវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍និងធ្វើបទបង្ហាញពីសេចក្តីព្រាងគោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងទិន្នន័យឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដូចខាងក្រោម៖

**ហេតុផល៖**

- ✓ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាជាមួយអង្គការសហប្រជាជាតិក្នុងដំណើរឆ្ពោះទៅសម្រេចបាននូវគោលដៅបីសូន្យនាឆ្នាំ២០២៥ (គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការស្លាប់ដោយសារជំងឺអេដស៍ និងគ្មានការរើសអើង) ដោយមាន អ.ជ.ប.ជ.អ ជាស្ថាប័នដឹកនាំគ្រប់គ្រង និងសម្របសម្រួលការឆ្លើយតប ។
- ✓ យោងទៅតាមតួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គឺឈរនៅលើគោលការណ៍បីមួយ ដើម្បីធានាការឆ្លើយតបទូលំទូលាយ និងពហុវិស័យ គឺស្ថាប័នដឹកនាំគ្រប់គ្រង និងសម្របសម្រួលតែ១ គម្រោងផែនការយុទ្ធសាស្ត្រតែ១ និងប្រព័ន្ធតាមដាន និងវាយតំលៃតែមួយ។

**គោលបំណង៖**

- ✓ ចងក្រងនូវព័ត៌មានស្តីពីការឆ្លើយតបទូលំទូលាយទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានគ្រប់ជ្រុងជ្រោយ។
- ✓ ប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្ត្រក្នុងការរៀបចំគោលនយោបាយ

**កម្មវត្ថុ៖**

- ✓ ពង្រឹងប្រព័ន្ធតាមដាន វាយតម្លៃ និងស្រាវជ្រាវជាតិ
- ✓ ពង្រឹងគុណភាពនៃទម្រង់ និងដំណើរការប្រមូលទិន្នន័យ
- ✓ ពង្រឹងនូវគុណភាពនៃការគ្រប់គ្រងទិន្នន័យ
- ✓ ពង្រឹងនូវគុណភាពនៃការចងក្រងព័ត៌មានតាមរយៈរបាយការណ៍

**គោលការណ៍ណែនាំជាតិ៖**

- ✓ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវរៀបចំទម្រង់ប្រមូលទិន្នន័យជាតិដែលអាចប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យឆ្លើយតបជាតិប្រយុទ្ធនឹងជំងឺអេដស៍ឱ្យបានគ្រប់ជ្រុងជ្រោយ។

- ✓ សមាជិក អ.ជ.ប.ជ.អ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបញ្ជូនទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ ឱ្យបានជាទៀងទាត់រៀងរាល់៦ខែម្តង (នៅថ្ងៃទី២៥ ខែមិថុនា និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩)។
- ✓ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងទិន្នន័យ និងរៀបចំជាសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធិផលស្តីពីការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាស ដើម្បីសុំការឯកភាពពីសមាជិក អ.ជ.ប.ជ.អ តាមរយៈកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ។
- ✓ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសបញ្ចប់ ដើម្បីដាក់ជូនស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងសមាជិក អ.ជ.ប.ជ.អ រួមទាំងអង្គការសហប្រជាជាតិផងដែរ។

ក្រោយបង្ហាញចប់ឯកឧត្តមប្រធានអង្គប្រជុំ បានបើកការចូលរួមយោបល់ពីអ្នកចូលរួមដូចខាងក្រោម៖

លោកវេជ្ជ. **ទិត ស្រេង** តំណាងអង្គការ RHAC បានចូលរួមយោបល់ និងបញ្ជាក់ទៅលើសជណត្រង់ចំណុចលេខ៥ ដែលរដ្ឋាភិបាលប្តេជ្ញាចិត្តក្នុងការបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥។ ដោយសារអង្គការ RHAC ធ្វើនៅលើក្រុមសេវាកំសាន្ត ក្រុមស្រលាញ់ភេទដូចគ្នា ក្រុមប្លែងភេទ គឺឃើញមានរលកនៃការឆ្លងប្លែក ពិសេសក្រុមស្រលាញ់ភេទដូចគ្នាហើយប្រើប្រាស់គ្រឿងញៀន ដូចនេះដើម្បីសម្រេចគោលដៅនេះទាល់តែមានការចូលរួមគ្រប់ក្រសួង ស្ថាប័នទាំងអស់។ សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩ ការរកឃើញតេស្តវិជ្ជមាននៅតែខ្ពស់។ ចំពោះការយល់ដឹងពីមេរោគអេដស៍ និងជំងឺអេដស៍មានការធ្លាក់ចុះចំពោះយុវវ័យតាមរយៈសំណួរមួយចំនួនដែលក្រុមការងារបានសាកសួរ។

តាមរយៈការលើកឡើងនេះឯកឧត្តមប្រធានអង្គប្រជុំ បានសំណូមពរដល់តំណាងអង្គការ RHAC ធ្វើបទបង្ហាញទាក់ទងជាមួយបញ្ហានេះ ដើម្បីរកវិធីដោះស្រាយឱ្យទទួលបានជោគជ័យ។

លោកស្រី **និត សុផា** តំណាងអង្គការ FHI 360 បានសំណូមពរឱ្យមានការផ្សព្វផ្សាយពីច្បាប់អេដស៍ ដល់កងកម្លាំងប៉ូលិស ទាហាន ដោយសារពួកគាត់ពុំទាន់បានជ្រាបពីបញ្ហានេះ។ ម្យ៉ាងទៀតគួរតែបញ្ជ្រាបពីបញ្ហាអេដស៍ ជាមួយកិច្ចប្រជុំដ៏ទៃទៀត ពុំចាំបាច់ប្រជុំតែបញ្ហាអេដស៍ដាច់ដោយឡែកនោះទេ។

តំណាងក្រសួងព័ត៌មានៈ ខ្វះថវិកាក្នុងការបញ្ជ្រាបពីបញ្ហាអេដស៍ទៅដល់អ្នកនិពន្ធ (និពន្ធនាយក ពិធីករ ពិធីការនី) ដើម្បីធ្វើសិក្ខាសាលាបណ្តុះបណ្តាលពីបញ្ហាមេរោគអេដស៍ ច្បាប់អេដស៍ ដើម្បីផ្សព្វផ្សាយឱ្យចំគោលដៅ នៅតាមភូមិភាគរយៈពេល៦ខែ ឬ១ឆ្នាំម្តង ព្រោះបច្ចុប្បន្នមានស្ថានីយវិទ្យុចំនួន ២២ លើ២៥ រាជធានី ខេត្ត។

តាមរយៈការលើកឡើងនេះឯកឧត្តមប្រធានអង្គប្រជុំ បានមានប្រសាសន៍ថា គួរធ្វើបច្ចុប្បន្នភាពពីការបណ្តុះបណ្តាលនៅតាមខេត្តឱ្យបានមុន១ខែ ដើម្បីអាចបញ្ចូលអ្នកយកព័ត៌មាន ពិធីករ ពិធីការនីតាមខេត្តដែលមានវគ្គបណ្តុះបណ្តាល បានចូលរួម ដើម្បីផ្សព្វផ្សាយបន្ត។

ជាកិច្ចបន្តឯកឧត្តមប្រធានអង្គប្រជុំ បានធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំដូចខាងក្រោម៖

- ✓ មានបន្ថែមនូវរបាយការណ៍របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងព័ត៌មាន និងកាកបាទក្រហមកម្ពុជា។
- ✓ ចំពោះបទបង្ហាញពីគោលការណ៍ណែនាំជាតិ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកលសម្រាប់វិស័យមិនមែនសុខាភិបាល ត្រូវកែសម្រួលអក្ខរាវិរុទ្ធ និងរូបភាពបើសិនជាអាច។
- ✓ ការជម្រាបជូនពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងការចូលរួមយោបល់របស់លោកវេជ្ជ. **ទិត ស្រេង** មានចំណាប់អារម្មណ៍ទៅលើប្រជាជនចំណាកស្រុក និងសំណូមពរឱ្យធ្វើបទបង្ហាញនៅកិច្ចប្រជុំលើកក្រោយ។
- ✓ បទបង្ហាញពីសេចក្តីព្រាងគោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងទិន្នន័យ ឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

កិច្ចប្រជុំបានបញ្ចប់ទៅក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**<u>ឧបសម្ពន្ធ៖</u>**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃចន្ទ ១២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩

**បានឃើញ និងឯកភាព**
**អគ្គលេខាធិការ**

វេជ្ជ. ស៊ែន គន្ធី

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

**វេជ្ជ. ឈា សិទ្ធិ**

**អ្នកធ្វើរបាយការណ៍**

**វេជ្ជ. ហេង ហៃ**